Washington State Department of Social & Health Services

# ប្រវេសន៍សំរាប់ឪពុកម្តាយ

## NOTICE TO PARENTS

ថ្ងៃ/ខែ/ឆ្នាំ

ក្រដាសនេះប្រើក្នុងច្បាប់លេខ WAC 388-454-0025 ក្រសួងនឹងប្រាប់ឪពុកម្តាយរបស់ក្មេងឲ្យដឹងនៅពេលណាដែលយើងយល់ព្រមឲ្យជំនួយហើយក្មេងកំពុងរស់នៅជាមួយជនណាម្នាក់ផ្សេងក្រៅពីឪពុកម្តាយរបស់គេ។

| ការិយាល័យបំរើសហគមន៍(CSO) | ជនដែលត្រូវទាក់ទងធ្វើការនៅ CSO | លេខទូរសព្ទ |
|---|---|---|
| | | |

ក្រសួងសង្គមកិច្ចនិងសុខាភិបាលនៅរដ្ឋវ៉ាស៊ីនតោន(DSHS)បានយល់ព្រមនៅពេលថ្មីៗនេះផ្តល់ឲ្យជំនួយជាបណ្តោះអាសន្នសំរាប់គ្រួសារដែលត្រូវការចាំបាច់ (TANF) សំរាប់កូនរបស់អ្នកដែលមានឈ្មោះខាងក្រោមនេះ:

____________________ ____________________

____________________ ____________________

____________________ ____________________

ច្បាប់របស់រដ្ឋបានផ្តល់សិទ្ធិឲ្យអ្នកសំរាប់ការប្រាប់ដំណឹងឲ្យអ្នកដឹងដោយក្រសួង:

1. ថាកូនរបស់អ្នកបានត្រូវយល់ព្រមឲ្យជំនួយសំរាប់កម្មវិធី TANF (ប្រាក់សុទ្ធនិងការគ្រប់គ្រងផ្នែកពេទ្យ)ក្នុងរយៈពេលប្រាំពីរថ្ងៃនៃថ្ងៃដែលយើងបានយល់ព្រមនូវពាក្យសុំរបស់កូនអ្នក លើកលែងតែការទាមទារដែលមានភ័ស្តុតាងថាអ្នកបានធ្វើបាបរំលោភបំពាន ឬធ្វេសប្រហែសលើកូនរបស់អ្នក។

2. ពីអាសយដ្ឋាននៃកូនរបស់អ្នកនៅក្រោមលក្ខណៈខាងក្រោមនេះ:
   a. នៅពេលអ្នកផ្តល់ក្រដាសចំឡងនៃដីកាបញ្ជាតុលាការដែលផ្តល់ឲ្យអ្នកមានការគ្រប់គ្រងក្មេងស្របច្បាប់ សិទ្ធិសំរាប់ទៅសួរសុខទុក្ខក្មេង ឬចំណាយពេលវេលានៅតាមផ្ទះហើយប្រគល់ជូននូវសេចក្តីបញ្ជាក់ពីការស្បថស្បែថាដីកាបញ្ជាមិនទាន់បានកែប្រែនៅឡើយ, ហើយ
   b. មិនមានដីកាបញ្ជាពីតុលាការហាមឃាត់ ឬដាក់កំរិតចំពោះការទាក់ទង ឬទៅសួរសុខទុក្ខកូនរបស់អ្នក ឬអ្នកមើលថែរក្សាកូនរបស់អ្នកដោយលក្ខណៈបង្ខិតបង្ខំដើម្បីការពារកូនក្មេង ឬពីអ្នកមើលថែរក្សាកូនក្មេងអំពីការធ្វើទុក្ខទោស, ហើយ
   c. ក្រសួងមិនទាន់បានសំរេចថាអ្នកមើលថែរក្សាក្មេងមានមូលហេតុល្អសំរាប់ការបដិសេធដើម្បីរួមសហប្រតិបត្តិការក្នុងសកម្មភាពដើម្បីអនុវត្តផ្នែកឧបត្ថម្ភក្មេងដែលទាក់ទងទៅនឹងកាតព្វកិច្ចផ្នែកឧបត្ថម្ភក្មេងរបស់អ្នក និង
   d. អ្នកគ្មានជាប់ទាក់ទងជាមួយការទាមទារដែលមានភ័ស្តុតាងថា ឬរង់ចាំការស៊ើបអង្កេតដែលជាប់ទាក់ទងជាមួយការធ្វើបាបរំលោភបំពាន ឬ ឬធ្វេសប្រហែលលើកូនរបស់អ្នកព្រមទាំង
   e. មិនមានការរង់ចាំចំណាត់ការដូចចុះនៅក្នុងផ្នែកទី(2)(a) រហូតដល់ (d)។

អ្នកអាចស្នើសុំអាសយដ្ឋាននិងទីកន្លែងរបស់ក្មេងរស់នៅ :

1. ដោយផ្ទាល់ខ្លួន ជាមួយប័ណ្ណសំគាល់មានរូបថត នៅកន្លែងការិយាល័យបំរើសហគមន៍
2. តាមរយៈមេធាវី ឬ
3. ដោយបញ្ជូនសម្នើសុំសារការីនៅពេលណាអ្នករស់នៅក្រៅរដ្ឋវ៉ាស៊ីនតោន។

មុននឹងគេឲ្យអាសយដ្ឋានទៅអ្នក ក្រសួងនឹងប្រាប់ទៅអ្នកមើលថែរក្សាដែលកូនរបស់អ្នករស់នៅជាមួយឲ្យដឹងនូវសម្នើសុំសំរាប់ការបញ្ចេញពត៌មានបន្ទាប់មកអ្នកមើលថែរក្សាក្មេងមានពេល 30 ថ្ងៃដើម្បី:

1. បង្ហាញនូវពត៌មានដែលអាចបញ្ឈប់ក្រសួងពីការផ្តល់អាសយដ្ឋានទៅអ្នក ឬកំរិតនូវសិទ្ធិរបស់អ្នកដើម្បីទៅសួរសុខទុក្ខ ឬទាក់ទងជាមួយកូនរបស់អ្នក។
2. ស្នើសុំសវនាការរកយុត្តិធម៌។ ចៅក្រមផ្នែករដ្ឋបាលនឹងធ្វើសេចក្តីសំរេច បើសិនក្រសួងអាចផ្តល់ឲ្យអ្នកនូវអាសយដ្ឋាន។

DSHS នឹងឆ្លើយតបនូវសម្នើសុំរបស់អ្នកក្នុងរវាង 35 ថ្ងៃ។

ការបំរើផ្នែកសម្របសម្រួលគ្រួសារ(FRS)មានតាមរយៈក្រសួងសង្គមកិច្ចនិងសុខាភិបាល។ ការបំរើទាំងនេះគឺរៀបចំឡើងដើម្បីពង្រឹងនិងសម្របសម្រួលដល់គ្រួសារ។ សូមទូរសព្ទទៅ FRS/Runaway Youth សំរាប់ពត៌មានបណ្តាញទូរសព្ទពិសេសតាមលេខ 1-800-486-9612 សំរាប់ពត៌មានក្នុងការបំរើទាំងនេះ។